ព្រឹត្តិបត្រអង្គការស្ត្រីខ្មែរកម្ពុជាក្រោម
Khmer Kampuchea Krom Women Organization Bulletin
ចេញផ្សាយប្រចាំអឌ្ឍមាស លេខ១០ ឆ្នាំទី១ ពីថ្ងៃទី១៦-៣១ ខែធ្នូ ឆ្នាំ២០០៨

ខ្មែរកម្ពុជាក្រោមឆ្ពោះទៅមុខ

កាលពីថ្ងៃអាទិត្យ ទី២១ ខែធ្នូ ឆ្នាំ២០០៨ ព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ប្រមាណ៥០០រូប បានជួបជុំគ្នានៅវត្តសាមគ្គីរង្សី ឋិតនៅភូមិត្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដើម្បីស្វាគមន៍ឯកឧត្តម MARCO PENNELLA សមាជិកសភាសហគមន៍អឺរ៉ុប និងជាប្រធាន Transnational Radical Party និងឯកឧត្តម MARCO PERDUCA សមាជិកព្រឹទ្ធសភាអ៊ីតាលី ទទួលបន្ទុកអគ្គហេរិញ្ញិកនៃអង្គការ UNPO ហើយនៅក្នុងពិធីនោះក៏មានការចូលរួមពីអ្នកតំណាងរាស្ត្រមួយចំនួនដូចជា **ឯកឧត្តម ស៊ុន ឆ័យ ឯកឧត្តម ហូ វ៉ាន់ ឯកឧត្តម នុត រំដួល ឯកឧត្តម ឡុង រី ឯកឧត្តម យន្ត ថារ៉ូ** និងប្រធានអង្គការ សមាគមខ្មែរកម្ពុជាក្រោមមួយចំនួនទៀតដូចជា **ព្រះឧត្តមប្រាជ្ញាយ័មមហា យឿង សិន** ព្រះប្រធានសមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម **ឯកឧត្តម ថាច់ សេដ្ឋា** ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម **អ្នកស្រី ថ្វី យ៉ាវ** នាយិកាអង្គការស្ត្រីខ្មែរកម្ពុជាក្រោម **លោក អាង ចំរុងឫទ្ធិ** ប្រធានអង្គការការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម **លោក ស៊ឺន យឿង** នាយកប្រតិបត្តិសមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្សនិងអភិវឌ្ឍន៍ **លោក គួច ខឹម** អនុប្រធានមជ្ឈមណ្ឌលវប្បធម៌ខ្មែរកម្ពុជាក្រោម **ព្រះតិស្ស ថាច់ មិន** តំណាងសហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោកប្រចាំកម្ពុជា ។

កិច្ចស្វាគមន៍ចំពោះឯកឧត្តមទាំងពីរ ដោយហេតុថាគាត់បានខិតខំប្រឹងប្រែងជួយជំរុញបងប្អូនខ្មែរកម្ពុជាក្រោម ធ្វើឱ្យសហគមន៍អឺរ៉ុប និងអង្គការសហប្រជាជាតិទទួលស្គាល់និងដឹងឮអំពីទុក្ខលំបាករបស់ខ្មែរកម្ពុជាក្រោម ដែលរដ្ឋាភិបាលវៀតណាមបានរឹតបន្តឹងរឹតត្បិតសង្កត់ បំបិទសិទ្ធិសេរីភាពគ្រប់បែបយ៉ាង ហើយនៅក្នុងអង្គពិធីនាពេលនោះ បន្ទាប់ពីគោរពភ្លេងជាតិ និងព្រះសង្ឃជយន្តោ ព្រមទាំងមានសុន្ទរកថាជាបន្តបន្ទាប់ក្នុងនោះ យើងកត់សម្គាល់ឃើញថាមានសំណូមពរចំនួន១២ចំណុចរបស់ខ្មែរកម្ពុជាក្រោមដល់រដ្ឋាភិបាលវៀតណាមតាមរយៈឯកឧត្តមទាំងពីរ ហើយពួកគាត់បានមានប្រសាសន៍នៅក្នុងអង្គពិធីនោះដែលមានខ្លឹមសារដូចតទៅ... ១-ការតស៊ូដោយអហិង្សាមានព្រះសង្ឃធម្មយាត្រាដោយជើងដូចជានៅ ទីបេ និងភូមា ជាដើម ២-សំណូមពររបស់បងប្អូនខ្មែរកម្ពុជាក្រោមមានច្រើនចំណុច ប៉ុន្តែក្នុងនោះសុំឱ្យយកពាក្យថា **កម្ពុជាក្រោម** ជាអាទិភាពនៅជជែកជាមួយរដ្ឋាភិបាលវៀតណាម ពីព្រោះកន្លងមកខ្មែរកម្ពុជាក្រោមត្រូវបានវៀតណាមប្តូរទៅជា**ខ្មែរវៀតណាម** ហើយបើគេប្រើពាក្យថា **កម្ពុជាក្រោម** ឬ **ខ្មែរកម្ពុជាក្រោម** ត្រូវបានរដ្ឋាភិបាលវៀតណាមគាបសង្កត់គ្រប់បែបយ៉ាង (វៀតណាមរងើប) ហួសដល់ចាប់ដាក់ពន្ធនាគារ ៣-សភាអឺរ៉ុបបានបោះឆ្នោតកាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៨ មាន៥០៤សម្លេង គាំទ្រ៤៧៥សម្លេង ២១សម្លេងបដិសេធ និង៨សម្លេងអនុប្បវាទក្នុងការជំរុញឱ្យរដ្ឋាភិបាលវៀតណាមគោរពសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋឱ្យបានពេញលេញ តាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ជាពិសេសប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ៤-ប្រជាពលរដ្ឋគ្រប់សញ្ជាតិនៅប្រទេសវៀតណាមកំពុងតស៊ូទាមទារសិទ្ធិសេរីភាពរបស់ពួកគេ ក្នុងនោះក៏មានខ្មែរកម្ពុជាក្រោមផងដែរ ៥-នៅទីក្រុងរ៉ូមនៃប្រទេសអ៊ីតាលីមានបិទរូបភាពនៃជនរងគ្រោះដោយសាសនា និងដោយអំពើអហិង្សាជាច្រើន ក្នុងនោះក៏មានបិទរូបភាពព្រះសង្ឃព្រះនាម **លីម សាខន** និងព្រះភិក្ខុសង្ឃ០៤ព្រះអង្គទៀត ដែលរបបកុម្មុយនីស្តយកទៅផ្សឹកដាក់ពន្ធនាគារ ដូច្នេះខ្មែរកម្ពុជាក្រោមរងការរំលោភបំពានទាំងប៉ុន្មាននៅប្រទេសវៀតណាម ត្រូវបានពិភពលោកបានឃើញ បានដឹងទាំងអស់ ៦-ការតស៊ូដោយអហិង្សាជាយុទ្ធសាស្ត្រមួយដ៏ចំបំផុតដែលមនុស្សជាតិទាំងឡាយនៅលើពិភពលោកតែងឱ្យតម្លៃគ្រប់គ្នា ៧-ការសាមគ្គីនៃការតស៊ូដោយអហិង្សា វានឹងឈ្នះទៅមុខហើយទទួលបានជោគជ័យ ៨-បងប្អូនជនរួមឈាមខ្មែរកម្ពុជាក្រោមនៅជុំវិញពិភពលោកបានខិតខំប្រឹងប្រែងតស៊ូដោយអហិង្សាយូរឆ្នាំមកហើយ បានឱ្យអង្គការUNPO និង Transnational Radical Party ជួយជំរុញឱ្យពិភពលោក បានឃើញនៃការខិតខំប្រឹងប្រែងរបស់ខ្មែរកម្ពុជាក្រោម ក្នុងការ ទាមទារសិទ្ធិមនុស្ស សិទ្ធិសេរីភាពលើគ្រប់វិស័យដូចមនុស្សជាតិទាំងឡាយនៅលើពិភពលោក ៩-ឯកឧត្តមទាំងពីរបានសន្យា ថានឹងមកធ្វើសិក្ខាសាលានៅកម្ពុជាក្នុងឆ្នាំ២០០៩ដ៏ខ្លីខាងមុខនេះ ។

បន្ទាប់មកអង្គការ សមាគមខ្មែរកម្ពុជាក្រោមទាំងអស់បានជូនរបាយការណ៍អំពីការរំលោភសិទ្ធិមនុស្ស និងឯកសារសំណូមពរ ព្រមទាំងមានជូនកាដូអនុស្សាវរីយ៍ដល់ឯកឧត្តមទាំងពីរ ហើយបានបញ្ចប់កម្មវិធីប្រកបដោយភាពស្និទ្ធស្នាល និងរីករាយយ៉ាងក្រៃលែង ។

* * *

មនុស្សពុលក្អួច

បន្ទាប់ពីបងប្អូនជនរួមឈាមខ្មែរកម្ពុជាក្រោមបានរៀបចំស្វាគមន៍លោកឧត្តម MARCO PENNELLA និងលោកឧត្តម MARCO PERDUCA នៅវត្តសាមគ្គីរង្សីភាពពីថ្ងៃអាទិត្យ ទី២១ ខែធ្នូ ឆ្នាំ២០០៨រួចមក មានមនុស្សម្នាក់បានដើរស្រែកឡូឡាថា ការរៀបចំពិធីនោះជារឿងវិបត្តិធ្ងន់ធ្ងរដល់ព្រះសង្ឃ និងបងប្អូនខ្មែរកម្ពុជាក្រោម ហើយនៅមានពាក្យព្រួសញ្ញូវថា វៀតណាមពុំបានរំលោភសិទ្ធិសេរីភាពអ្វីទេ ព្រោះគេបានជួយសម្រួលឱ្យរស់ហើយ ។

នៅក្នុងអត្ថន័យផ្ទុយពីប្រវត្តិសាស្ត្រក៏ដូចជាផ្ទុយពីព្រឹត្តិការណ៍ពិតនានា ព្រឹត្តិបត្រអង្គការគ្រូខ្មែរកម្ពុជាក្រោមបានជួបជាមួយព្រះសង្ឃ និងបងប្អូនជនរួមឈាមខ្មែរកម្ពុជាក្រោមសព្វថ្ងៃ ដែលកំពុងរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានមានមតិជាច្រើនអំពីបញ្ហាខ្មែរកម្ពុជាក្រោមបានរងគ្រោះពីអតីតកាលរហូតមកដល់បច្ចុប្បន្នកាល ហើយព្រឹត្តិបត្រអង្គការគ្រូខ្មែរកម្ពុជាក្រោម សូមប្រមូលខ្លឹមសារសង្ខេបខាងដូចតទៅ...

- បើវៀតណាមពុំបានរំលោភសិទ្ធិសេរីភាពឱ្យខ្មែរនៅកម្ពុជាក្រោមរៀនសូត្របានទូលំទូលាយនោះ មិនទាំងចាប់ព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរឈានចំណមករៀននៅភ្នំពេញទេ ។
- បើវៀតណាមមិនរៀបសង្កត់ធ្វើបាបខ្មែរកម្ពុជាក្រោមទេនោះ ឡាស់ជាខ្មែរកម្ពុជាក្រោមមិនលបរត់មកស្រុកខ្មែរ (ភ្នំពេញ) និងទៅនៅបរទេសតាមតាំងពិភពលោក បុគ្គលមនុស្សម្នាក់ដែលដើរឡូឡានោះផងដែរ ក៏សុទ្ធតែរត់ចាកចេញពីមាតុភូមិជាមិនស្ម័គ្រចិត្តរបស់ខ្មែរយើងទាំងអស់គ្នា ។
- នៅកម្ពុជាក្រោមបើគេនិយាយពាក្យថា **កម្ពុជាក្រោម** ត្រូវបានវៀតណាមចាប់ចងយកទៅចាក់គុក ព្រោះថា យើងមានបំណងបង្កើតបក្សពួក ឬសមាគម ពិសេសពីវៀតណាមគេស្រាវជ្រាវបែបចេញយ៉ាងធ្ងន់ធ្ងរជាក់ចុកក្បាល ។
- សព្វថ្ងៃគ្មានទេនៅកម្ពុជាក្រោម អំពីការចលនាឱ្យសិក្សារៀនសូត្រ អក្សរសាស្ត្រខ្មែរ មានរៀនដែរតែរៀន ៣-៤-៥-៦-៧ ដើម្បីចាំវត្តអារាមតែប៉ុណ្ណោះ មិនមានរៀនឱ្យបានខ្ពង់ខ្ពស់ពីមុនឆ្នាំ១៩៧៥ឡើយ
- ត្រាជាអក្សរខ្មែរនៅតាមវត្តនីមួយៗ ក៏សុទ្ធតែដាក់អក្សរយួនទាំងអស់មិនដូចកាលពីមុនទៀតឡើយ ហើយគេហៅខ្មែរយើងថាជាខ្មែរ យួនមួយ មិនមែនខ្មែរកម្ពុជាក្រោមដូចពីដើមនោះទេ ។
- រឿងដីធ្លីនិងបញ្ហារស់នៅក្នុងសង្គម ក៏វៀតណាមបានការរើសអើង ប្រកាន់ពូជសាសន៍មកលើខ្មែរកម្ពុជាក្រោមយ៉ាងធ្ងន់ធ្ងរ ។

បញ្ហាទាំងអស់ខាងលើនេះគ្រាន់តែមួយផ្នែកតូចតែប៉ុណ្ណោះ បើយើងស្រាវជ្រាវហើយរៀបរាប់ឱ្យអស់នោះវាច្រើនណាស់ ដូច្នេះសូមកុំដើរឡូឡាបង្ខូចកេរ្តិ៍ឈ្មោះខ្មែរទាំងអស់គ្នា គឺពាក្យថាកូនកំព្រាម្ដាយ កុំដែលស្រួលធ្វើជាអ្នកពុលក្អួចម្នាក់ ដើរឡូឡានោះឡើយ ។

មហាសន្និបាតវិសាមញ្ញអាណត្តិទី២ នៃសម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម

នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៨ កន្លងមកនេះ សម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម បានប្រារព្ធអង្គមហាសន្និបាតវិសាមញ្ញអាណត្តិទី២ នៅវត្តអង្គរាជបុរី សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ក្រោមព្រះអធិបតីភាពព្រះតេជគុណ **ថាច់ សឿ** និងឧត្តមកិត្តិយសជាភ្ញៀវកិត្តិយស និងលោក លោកស្រី តំណាងអង្គការ-សមាគមខ្មែរកម្ពុជាក្រោមប្រចាំនៅកម្ពុជាមួយចំនួនទៀត ដោយឡែកភ្ញៀវកិត្តិយសក្នុងឱកាសនោះ ក៏មានព្រះវត្តមានព្រះថេរានុថេរៈ រួមទាំងពុទ្ធបរិស័ទ និងសិស្ស-និស្សិតនៅរាជធានីភ្នំពេញប្រមាណរាប់ រយអង្គ-នាក់បានចូលរួមផងដែរ ។

បន្ទាប់ពីលោកស៊ឺន សែតប្រធានក្រុមប្រឹក្សាភិបាលសម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោមប្រកាសបើកមហាសន្និបាតវិសាមញ្ញអាណត្តិទី២មក **ព្រះតេជគុណ ចៅ សាន** អតីតព្រះប្រធានសម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោមបានមានសង្ឃដីកាសម្ដែងដោយសង្ខេបថា ការប្រារព្ធមហាសន្និបាតវិសាមញ្ញនាពេលនេះ ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់សមាជិក ដើម្បីរៀបចំរចនាសម្ព័ន្ធថ្មីមានការជ្រើសរើសប្រធាន និងគណៈកម្មការសម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោមសម្រាប់អាណត្តិ ថ្មី ហើយក៏ជាការផ្ដល់ឱកាសដល់អ្នកដឹកនាំថ្មីដើម្បីបន្តការអភិវឌ្ឍន៍ធនធានមនុស្សលើគ្រប់វិស័យស្របទៅនឹងកាលៈទេសៈ ដែលជាកម្មវត្ថុនៃគោលការណ៍របស់ខ្លួនឱ្យកាន់តែប្រសើរថែមទៀត។ ក្នុងរយៈកាលកន្លងមកនេះ សម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោមបានធ្វើកិច្ចការសំខាន់ៗ ដូចជាការបញ្ជូនសមណនិស្សិតចេញទៅសិក្សានៅបរទេស ការស្វែងរកថវិកាសម្រាប់ជាសម្ភារៈ ជួយដល់សមណនិស្សិតទាំងឡាយនៅបរទេស ទាំងនៅក្នុងស្រុក។ ប៉ុន្តែថ្ងៃនេះក៏នៅតែមានការលំបាកដែលយើងត្រូវតែដោះស្រាយ ឆ្លើយតបទៅតាមតម្រូវការរបស់និស្សិតពិតប្រាកដ ប៉ុន្តែវាពិតជាបញ្ហាដែលកំពុងតែសេចក្ដីត្រូវការជាចាំបាច់បំផុតរបស់និស្សិត ដែលសម្ព័ន្ធសមណនិស្សិតខ្មែរកម្ពុជាក្រោមចាត់ទុកជាកិច្ចការអាទិភាព ។

ពិធីនេះបញ្ចប់ទៅ ក្រោយពីបានធ្វើការបោះឆ្នោតជ្រើសរើសប្រធាន និងគណៈកម្មការចំនួន១០អង្គ ដើម្បីអនុវត្តកិច្ចការក្នុងអាណត្តិថ្មីក្នុងរយៈពេលបីឆ្នាំទៅមុខ សូមបញ្ជាក់ថាសម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម ជាអង្គការសង្គមស៊ីវិលមួយដ៏សំខាន់ក្នុងការបណ្ដុះបណ្ដាលធនធានមនុស្សរបស់ខ្មែរកម្ពុជាក្រោម ។

មហាសន្និបាតវិសាមញ្ញ
ជ្រើសរើសប្រធាន និង គណៈកម្មការថ្មីអាណត្តិទី២
នៃសម្ព័ន្ធសមណ និស្សិត និស្សិត ខ្មែរកម្ពុជាក្រោម

គណៈកម្មការថ្មីនៃសម្ព័ន្ធសមណនិស្សិត ថតរូបអនុស្សាវរីយ៍ជាមួយព្រះតេជគុណ ថាច់ សឿ